# ការសាកល្បងពិនិត្យដោយរកហេតុផល

## អភិវឌ្ឍន៍នៅស្រុកខ្មែរជាអភិវឌ្ឍន៍បែបណា ?

-  ភាពស្ងប់ស្ងាត់

# មាតិការឿង

សេចក្តីផ្តើម 1
គំនិតទូទៅ 3
សង្កេតភាពលើអភិវឌ្ឍន៍នៅស្រុកខ្មែរ 11
សេចក្តីបញ្ចប់ 21

# សេចក្តីផ្តើម

និច្ច័យ នៃប្រវត្តិសាស្ត្រ (le sens de l'histoire) សម័យខ្មែរ គឺ ការដើរ ពុំអាចទប់ទល់បាន ទៅរកមហន្តរាយបន្តៗគ្នា មិនចេះចប់។ លុះចំណេរមក វាក្លាយជាទ្រទ្រូស សំរាប់ប្រជាពលរដ្ឋខ្មែរ ទូលទុក្ខក្នុងសេចក្តីអស់សង្ឃឹម ដោយមិនដឹងខ្លួនថា ខ្លួន ជា ម្ចាស់ នៃដំណោះស្រាយ ព្រោះ នយោបាយជាតិ វាកើតចេញអំពី ឆន្ទៈរបស់ខ្លួន។ ប្រជាពលរដ្ឋ មានការយកចិត្តទុកដាក់ ក្នុងនយោបាយជាតិ ជា ប្រជាពលរដ្ឋ ទទួលខុសត្រូវ លើវាសនារបស់ខ្លួនផង និងជាតិផង។

នៅក្នុង ការសាកល្បងពិនិត្យដោយរកហេតុផលនេះ យើងលើកយក អភិវឌ្ឍន៍ជាតិ មកសិក្សា ដើម្បីចង់ដឹងថា តើវាអាចជាកត្តាអាចនឹងបើក នូវគម្របរបាំងនៃភាពខ្លៅ (voile d'ignorance) ដែលនាំអោយប្រជាពលរដ្ឋខ្មែរ យល់ច្រឡំថា ការរីកចំរើនរបស់ជាតិ គឺគ្រាន់តែជា អត្តភាពពោរពា នូវសម្ភារៈសម័យ តាំងនៅក្នុងទូកញ្ចក់នៃហាងជំនួញសំរាប់តែជនមួយក្រុមតូចអាចទិញបាន។ អភិវឌ្ឍន៍ពិត គឺជា ការបង្កើតអោយមាន តម្លៃជាតិគ្រប់វិស័យ ដូចយ៉ាង សេដ្ឋកិច្ច សង្គមកិច្ច និងសិក្សាធិការជា

តិ។ តម្លៃជាតិនេះហើយ ដែល អ្នកសេដ្ឋកិច្ច គេហៅថា ភាពសម្បូណ៌ជាតិ (richesse nationale) ដែល ជនានុជនជាអ្នកទទួលបានចំណែកមួយភាគធំ សំរាប់បង្កើត ឋានៈជីវភាព (niveau de vie) រៀងៗខ្លួនផង និង សាធារណូបករណ៏[1] (bien commun) ផង។ នៅក្នុងប្រទេសអនុវត្ត សេដ្ឋកិច្ចជំនួញ (économie de marché) អភិវឌ្ឍន៏ ត្រូវមាន គោលដៅ សំរាប់បន្ថយវិសមភាព នៃភាពក្រនៅក្នុងសង្គម ដូច្នេះ អភិវឌ្ឍន៏ណា ដែលធ្វើអោយមានគម្លាត រវាងអ្នកមាននិង អ្នកក្រ កាន់តែធំឡើង វាគ្រាន់តែជា អភិវឌ្ឍន៏ជំនួញតែប៉ុណ្ណោះ ព្រោះ សេដ្ឋកិច្ចជំនួញវាគ្មានហេតុផលអ្វីសោះតាំងតែពីដំបូងទីមក បង្កើតត្រឹមតែ រចនាសម្ពន្ធ នៃផលទុន (revenus) និង ភាពសម្បូណ៌ ត្រូវតាមទំនង ដែលសង្គមត្រូវការ។ យ៉ាងហ្នឹងហើយ បានជា នៅប្រទេស នៃសេដ្ឋកិច្ចជំនួញ គេបង្កើតច្បាប់ សារពើពន្ធ (fiscalité) ដើម្បី ធ្វើការចែកឡើងវិញដល់ប្រជាពលរដ្ឋ នូវផលទុន និងភាពសម្បូណ៌ ដែលបង្កើតឡើងពីសេដ្ឋកិច្ចជំនួញ ពុំនោះសោត ផលទុន និងភាពសម្បូណ៏នោះ វាសំរាប់តែ នាយទុន និងអ្នកផ្លៀតមួយក្រុមតូច ទាញយកចំណេញតែប៉ុណ្ណោះ។ ហេតុនេះឯង អភិវឌ្ឍន៏ ត្រូវចាំបាច់ដឹកនាំ

[1] សាធារណូបករណ៏ឧ = ឧបករណ៏របស់សាធារណជន។

ដោយនយោបាយសេដ្ឋកិច្ច ប្រកបដោយប្រសិទ្ធិភាព ដើម្បីធ្វើការចែកផលដល់ប្រជាពលរដ្ឋ។ ដូចបានជំរាបខាងលើរួចមកហើយថា នយោបាយជាតិ កើតចេញពី ឆន្ទះរបស់ប្រជាពលរដ្ឋ ព្រោះ ប្រជាពលរដ្ឋ ជា ម្ចាស់អំណាច ជាអ្នកជ្រើសរើសអ្នដឹកនាំជាតិ ទៅតាមគោលគំនិតខ្លួន ដែលខ្លួនចង់បាន ដូច្នេះ នយោបាយសេដ្ឋកិច្ច ជាកិច្ចការផ្ទាល់របស់ប្រជាពលរដ្ឋ ដឹកនាំដោយ រដ្ឋាភិបាល ជា តំណាងរបស់ប្រជាពលរដ្ឋ ដើម្បី បំរើប្រយោជន៍ជាតិ និងប្រជាពលរដ្ឋ។

## គំនិតទូទៅ

កង្វះឯកសារ នៃស្ថិតិសេដ្ឋកិច្ច បង្ហាញ នូវរូបភាពពិតនៃសេដ្ឋកិច្ចជាតិ និងអ្នកជំនាញ ធ្វើការសិក្សា ជាជម្រៅ លើបញ្ហាសេដ្ឋកិច្ចជាតិ និង អវត្តមានទាំងអស់ នៃគណបក្សប្រឆាំង ក្នុងតួនាទីខ្លួន ជាអ្នកបំភ្លើ នៃនយោបាយសេដ្ឋកិច្ចជាតិ ជូនដល់សាធារណៈជន ជាឯកសារ មានគុណភាពក្តី ជាសន្និសិទ្ធ មានកំពស់នឹងគុណប្រយោជន៍ជាតិក្តី (conférence à la hauteur des enjeux nationaux) នាំអោយ គណបក្សកាន់អំណាច គេអាចបោកបញ្ឆោត ដល់

ប្រជាពលរដ្ឋខ្មែរ អំពីស្នាដៃ នៃនយោបាយសេដ្ឋកិច្ចរបស់គេថា ជាអភិវឌ្ឍន៍ដ៏អស្ចារ្យមួយ សំរាប់ប្រជាជាតិខ្មែរ។ ជាឧទាហរណ៍ថ្មីៗនេះលោក ហ៊ុន សែនគាត់និយាយថាកុំអោយខ្មែរបោះឆ្នោតអោយ គណបក្សណា ដែល មិនបានធ្វើអ្វីសោះដល់ជាតិ។ យើងអាចសួរទៅ លោក ហ៊ុន សែន ថា គាត់បានធ្វើអ្វីខ្លះ ដែលជាស្នាដៃលើកតំកើងតម្លៃជាតិ និងសេចក្តីថ្លៃថ្នូរ នៃប្រជាពលរដ្ឋខ្មែរ ?

កង្វះឯកសារគ្រប់បែបយ៉ាងនេះឯង ដែលជា ការពិបាកដល់យើង ដែលមានបំណង ចង់យល់ដឹងអំពី អភិវឌ្ឍន៍នៅខ្មែរសព្វថ្ងៃ តែទោះបីមាន ឧបសគ្គយ៉ាងណាក៏ដោយ ក៏យើងនៅតែព្យាយាម ធ្វើការសាកល្បងពិនិត្យ ដោយរកហេតុផល អំពីអភិវឌ្ឍន៍នៅស្រុកខ្មែរ ដោយយក ទ្រឹស្តីសេដ្ឋកិច្ចសំខាន់ៗ ធ្វើជា ចង្កៀងបញ្ចាំងមើល ការរីកចំរើននៅស្រុកខ្មែរ ថាតើវាកើតមកពីអភិវឌ្ឍន៍ មាននយោបាយសេដ្ឋកិច្ចត្រឹមត្រូវ ជា វិនាយក (guide morale) ឬ គ្រាន់តែជាអភិវឌ្ឍន៍ បង្ហាញតែទិដ្ឋភាពក្រៅ នៃការចំរើនលូតលាស់ តែប៉ុណ្ណោះ ?

## សេចក្តីថ្លៃថ្នូរ នៃមនុស្សលោក

ទស្សនវិទូ Kant បានស្នើអោយមានការបែងចែកឲ្យច្បាស់រវាងវត្ថុណា ដែលមានតម្លៃនឹងអ្វី ដែលមានសេចក្តីថ្លៃថ្នូរ។ អាស្រ័យហេតុនេះ អភិវឌ្ឍន៍ត្រឹមត្រូវ (développement juste) ត្រូវបដិសេធ នូវការប្រៀបធៀប ធនធាន (argent) ជាមួយនឹងគ្រប់គោលដៅ នៃអភិវឌ្ឍន៍ ព្រោះថា បើទុក ប្រយោជន៍ហិរញ្ញវត្ថុ ជាធំ វាច្បាស់ជាទង្គិច ជាពិសេសនឹង លក្ខណៈពិសិដ្ឋ នៃសេចក្តីថ្លៃថ្នូរ របស់មនុស្សលោក។ ឧទាហរណ៍ រដ្ឋាភិបាលខ្មែរសព្វថ្ងៃ គាត់ ជួលដីសម្បទាន អោយឈ្នួញ ហើយ អនុញ្ញាតអោយឈ្នួញនោះដេញបណ្តាជន ដែលបានរស់នៅ លើដីនោះ អស់រយៈយូរមកហើយ ដោយគ្មានលក្ខណៈជាមុន។ ទង្វើនេះឯងហើយ ដែលវាបេះទង្គិចដល់សេក្តីថ្លៃថ្នូរ នៃមនុស្សលោក ព្រោះមនុស្សលោក ត្រូវមានជម្រកស្ថិរ (abri stable et durable) ជាផ្ទះសំរាប់ជីវិតគ្រួសាររបស់ខ្លួន។ ដើម្បីជៀសនឹងបញ្ហានេះ កុំអោយវា កើតមានឡើងបាន រដ្ឋាភិបាលត្រូវមាន នយោបាយទូទៅ ធានា នូវសេចក្តីថ្លៃថ្នូរ នៃប្រជាពលរដ្ឋ ចំពោះមុខ ការរំលោភ គ្រប់បែបយ៉ាង ពីសំណាក់អ្នកវិនិយោគ។ តែអ្នកបង្អាប់គុណូបការ (détracteur) គេរិះគន់ថា បើគិតតែររល់ ដប់ម្តៃគ្រួសារ គឺច្បាស់ជា បង្កើតឧបសគ្គ ដល់ ការ

ផ្ទើអភិវឌ្ឍន៍ ជាពុំខាន។ អាស្រ័យហេតុនេះទៀត ដែល រដ្ឋាភិបាល ត្រូវមានច្បាប់ ហើយ អនុវត្តវាអោយបានត្រឹមត្រូវ ដើម្បី កុំអោយរំខានដល់អភិវឌ្ឍន៍ ព្រោះ សេចក្តីថ្លៃថ្នូរ នៃមនុស្ស វាមិនអាចទិញដូរបាននោះឡើយ។ វិនាយក គឺត្រូវទុក សេចក្តីថ្លៃថ្នូរ នៃនរជន (la dignité de l'humain) ជាសាធារណូបករណ៍ នៃប្រជាពលរដ្ឋខ្មែរ និងមនុស្សជាតិ ម្លោះហើយ វាជា ភោគសម្បត្តិពិសិដ្ឋ (les biens sacrés)។

## សាធារណូបករណ៍

ទោះបី យើងមើលឃើញថា នៅស្រុកខ្មែរសព្វថ្ងៃ មានរូបភាពខ្លះ បង្ហាញ នូវការរីកចំរើន ក្នុងវិស័យ ហេដ្ឋារចនាសម្ព័ន្ធ ទេសចរណ៍ សិក្សាធិការជាតិ សុខាភិបាលជាតិ តែប្រជាពលរដ្ឋ គាត់តែងតែសួរជាសំនួរថាតើនៅឯណាទៅសាធារណូបករណ៍ ? សំនួរនេះវាមានលក្ខណ: ជា សំនួរជម្មានរូប ព្រោះអ្វីដែលបង្កើតឡើងសព្វថ្ងៃ វាជារបស់ឯកជនសំរាប់បោយយកចំណេញតែប៉ុណ្ណោះ។ តើនេះហើយ ជា បមាណីយ (standard) នៃសេដ្ឋកិច្ចជំនួញ នៅក្នុងស៊ុមនៃពិភពលោកូបនីយកម្ម (cadre de mondialisation) ដែលតែងតែពំនឹងជាប្រពន្ធិក ប្រគល់អោយឯកជន កាន់កាប់ផ្សារទំនិញជានិច្ច (recours plus systématique à la privatisation) នោះឬ ? ហេតុនេះឯង

បានជាមាន អ្នកប្រឆាំងនឹង សេដ្ឋកិច្ចជំនួញហើយទុក អភិភវ័ន[2] (domination) របស់វា ជា ជ័យជំនះនៃសេដ្ឋកិច្ច លើ នរតម្លៃ (valeurs humanistes) ក្នុងពិភពលោក គ្មានករុណា គ្មានអាសូរ គិតតែរកអត្ថប្រយោជន៍ឯកជន ហើយមាន ការផ្លាស់ទ្រនំ នៃការទំនាក់ទំនងសង្គម និង តម្លៃពាក់ព័ន្ធនឹង សេចក្តីថ្លៃថ្នូរ នៃមនុស្សលោក (délitement du lien social et des valeurs liées à la dignité humaine) ដូចមាន ប្រជាពាក្យស្លោក មួយថា « ពិភពលោកមិនមែនជាទំនិញនោះទេ » ការជជីក ស្វែងរកចម្លើយនេះ វាស្របនឹង បរិបទ ស្រុកខ្មែរសព្វថ្ងៃ ដែលកំពុងជួបប្រទះ នូវវិបត្តិ សីលធម៌, សង្គម, យុវជន និងបណ្តាជន ឥតការងារធ្វើ, អសម្បទា នៃជនាធិប[3] (le politique) និងអ្នកនយោបាយខ្មែរ ប្រឈរមុខនឹង បំលាស់ប្តូរសង្គម នៅក្នុងស៊ុម នៃពិភពលោកូបនីយកម្ម និងនៅក្នុងឃ្នាងយៀកណាម។ តើត្រូវធ្វើបែបណាដែរ ដើម្បី អាចធ្វើឲសម្រេចបាន នូវសាធារណូបករណ៍ សំរាប់ប្រជាពលរដ្ឋ ?

ជាបឋម ត្រូវស្គាល់ និយមន័យ នៃពាក្យ សាធារណូបករណ៍។ ដើម្បីបន្ថយ នូវកត្តាធំៗ នៅក្នុងនិយមន័យ នៃពាក្យនេះយើងសួរសំនួរថា តើមនុស្សម្នាក់ៗ ចង់រស់នៅ ក្នុងសង្គមបែបណា ?

---

[2] អភិភវ័ន=ការគ្រោបសង្កត់។
[3] ជនាធិប ; អ្នកគ្រប់គ្រងរក្សាប្រជាជន។

តាមពិត សំនួរ សមហេតុផល មិនមែនស្ថិតនៅលើការចង់ដឹង អំពីឧត្តមសង្គមបែបណា ដែលយើង ចង់រស់នៅនោះឡើយ ជាឧទាហរណ៍ ដូចជាសង្គមមួយនៅក្នុងនោះ គ្រប់បុគ្គល នាំគ្នាអោយតម្លៃ ដល់ប្រយោជន៍ទូទៅ (intérêt général) លើសពីប្រយោជន៍ឯកជន ដោយយោងលើ ភាវៈ ជា មនុស្សលោក គឺថាជាមនុស្សលោក មិនមែនគិតខ្ចាប់ខ្លួន ស្វែងរកតែប្រយោជន៍សម្ភារៈតាមការញុះញង់ចិត្ត (incitations) មាននៅក្នុងបរិស្ថាន ដែលខ្លួនកំពុងរស់នៅនោះឡើយ ឧបមា ឃើញគេមានឡានល្អជិះខ្លួនឯក ដេកកើតទុក្ខ ចង់បានឡាននោះ សំរាប់ជិះដែរ។ ការញុះញង់ចិត្តចិត្តបែបនេះហើយ ដែលធ្វើអោយ សភាវគតិ របស់បុគ្គលនោះ អាចជ្រើសយក កិលេសមួយ ដែលវាផ្ទុយនឹងប្រយោជន៍ទូទៅ ឧបមា បើគ្មានលុយទិញឡាននោះ បុគ្គលនោះ អាចប្រព្រឹត្តិ អំពើទុច្ចរិត ដើម្បី រកលុយទិញឡាននោះ។ មួយវិញទៀត ការស្វែងរក សាធារណូបករណ៍ គឺ ធ្វើតាមមធ្យោបាយ នូវការបង្កើតស្ថាប័ន តម្រង់យក ការផ្សះផ្សា រវាងប្រយោជន៍ឯកជន ជាមួយនឹងប្រយោជន៍រួមគ្នា (intérêt collectif) ដើម្បីរកសមតានៅក្នុងសង្គម។ នៅក្នុងទស្សនវិស័យនេះ គេអាចសន្និដ្ឋានបានថា សេដ្ឋកិច្ចជំនួញ វាមិនមែនមាន គោលដៅជាទីបញ្ចប់របស់វា ត្រឹមតែរកចំណេញសុទ្ធសាតនោះឡើយព្រោះមធ្យោបាយ

ដែលវាយកមកប្រើ វាគ្រាន់តែ ជា ឧបករណ៏ខ្វោះ (instrument imparfait) មួយតែប៉ុណ្ណោះ បើសិនជាគេយក ការញែកឃ្លាតពីគ្នា រវាង ប្រយោជណ៏ឯកជន នឹង ប្រយោជន៏ទូទៅ ដែលវាមាននៅក្នុងសេដ្ឋកិច្ចជំនួញ មកសង្កេត។ ការខ្វែងគ្នា នៃប្រយោជន៏ទូទៅនេះទៀត ជួនវាមាន គម្របរបាំង នៃភាពខ្លៅ បាំងតួយ៉ាង បុគ្គលម្នាក់ គាត់មាន គ្រឿងយន្តបូមទឹក ហើយ គាត់គិតតែពីបូមទឹកស្រះសាធារណៈយកមកស្រោចចំការរបស់គាត់ ដោយ មិនបានគិតថា ទង្វើនេះ វាអាចនឹងនាំអោយខ្វះទឹកដល់មនុស្សផងគ្នានៅក្នុងភូមិ។ ការខ្វែងប្រយោជន៏ទូទៅមួយទៀត វាអាចមានកើតឡើងពីធម្មជាតិ ហើយមិនមានគម្របរបាំង នៃភាពខ្លៅ នោះដែរ ដូចយ៉ាង បុគ្គលម្នាក់កើតពីកំណើតជាជនពិការ ដូច្នេះ គាត់មានប្រយោជន៏ផ្ទាល់ខ្លួន ខុសពីបុគ្គលផ្សេងទៀត កើតមក ជាជនមានសុខភាពល្អ នៅក្នុងករណីបែបនេះ គេអាចសួរជាសំនួរថាតើ ប្រយោជន៏ឯកជន ជាបរិច្ឆិន្ន (intérêt privé spécifique) របស់ជនពិការនោះ ដើម្បីសុខុមាលភាព របស់គាត់ វាអាចនាំអោយរំខានដល់ប្រយោជន៏ទូទៅដែរឬទេ ? ជាឧទាហរណ៏ សំណង់នៃហេដ្ឋារចនាសម្ព័ន្ធ ជា បរិច្ឆិន្ន នៅទីកន្លែងសាធារណៈ ដែល សមូហសាធារណៈ (collectivité publique) ត្រូវចំណាយ ថវិកាមូលា (budget onéreux) ជា ការរំខាន ដល់ថវិកា

ប្រជួន (budget collectif ou collectif) ដើម្បីសម្រួលដល់ ការរស់នៅរបស់ជនពិការ។ ដូច្នេះ គេអាចទុក ប្រយោជន៍ឯកជន ជា សារូប (intérêt privé convenable) គឺនៅលើសំនួរសួរថា តើប្រយោជន៍នោះ វានាំអោយមានអ្នកទទួលរងគ្រោះដែរឬទេ ? គឺថា កំរិតរបស់ប្រយោជន៍ឯកជន វាមាន នៅពេលណា ប្រយោជន៍នោះ វាជាការនាំខូចដល់ប្រយោជន៍អ្នកដទៃ។ ការស្វែងរក សាធារណូបករណ៍ គឺយក សុខុមាលភាព ជា លក្ខណវិនិច្ឆ័យ ក្រោយគម្របរបាំង នៃភាពខ្មៅ តែមិនវិនិច្ឆ័យទុកជាមុន នូវគ្រប់ដំណោះស្រាយ និងកត្តា ដទៃទៀត ក្រៅពីសុខុមាលភាពរួមគ្នា (bien-être collectif) តែ វាទទួលស្គាល់ ការប្រើ ជា ឯកជន ដើម្បីសុខុមាលភាពបុគ្គល កុំអោយតែសិទ្ធប្រើនោះ វាបំពានទៅលើអ្នកដទៃ។ មានជា ឧទាហរណ៍ ដូចដែលបានលើកយកមកបង្ហាញ នៅខាងលើរួចមកហើយ គឺ ករណី បូមទឹកស្រះយកមកស្រោចចំការ។ អាជ្ញាធរភូមិ ជា និយតករ (régulateur) ដើម្បីជៀសវៀង ការខ្ជះខ្ជាយទឹកផង និងការពារ សាធារណូបករណ៍ផង។ ឧទាហរណ៍មានច្រើនទៀត នៅក្នុង មាត្រដ្ឋាន នៃប្រទេស (à l'échelle du pays) និងពិភពលោក អំពីសិទ្ធប្រើទឹកនៅក្នុងប្រទេសណា ឬ ដំបន់ណា ដែលមិនសូវមានទឹក, ធ្វើអ្វីមួយ នាំអោយក្រខ្វក់ ខ្យល់អាកាស ដែលវានាំអោយ ប៉ះពាល់ដល់ សុខភាពអ្នក

ដទៃ, បង្កើតអ្វី ដែលវាអាចរំខានដល់ ទេសភាពសាធារណៈ។ រួមសេចក្តីមក គឺថាអំពើណាដែលវាបំផ្លាញ ធនធានធម្មជាតិ និងនាំអោយមានជនរងគ្រោះ ជាអំពើអកុសលដល់មនុស្សជាតិ។ ធនធាតធម្មជាតិនេះឯងជាសាធារណូករណ៏សំរាប់ប្រជាពលរដ្ឋដែលមាន ច្បាប់សំរាប់ការពារវា ដើម្បី រក្សា សុខុមាលភាពរួមគ្នា។ ដូច្នេះអភិវឌ្ឍន៏ណា ដែលមិនយក លក្ខណវិនិច្ឆ័យ នៃសុខុមាលភាព និងសេចក្តីថ្លៃថ្នូរ របស់មនុស្សលោក ជា គោលដៅសំខាន់ គឺជាអភិវឌ្ឍន៏ព្រៃផ្សៃ របស់ពួកឈ្លួញមាន ពុទ្ធវិបល្លាស (aliénation mentale) ឬ មាន សតិឆ្កួតតែប៉ុណ្ណោះ ព្រោះថាបើឈ្លួញនោះ ជា មនុស្សលោកធម្មតា វាច្បាស់ជាមាន សតិផ្គត់ផ្គង់ដោយករុណាជាពុំខាន ព្រោះតម្លៃ នៃមនុស្សលោក វាខុសគ្នាពីតិរច្ឆាន។

## សង្កេតភាពលើអភិវឌ្ឍន៏នៅស្រុកខ្មែរ

## ការពិនិត្យកត់ត្រា

ជាបឋម យើងអាចសួរជាំន្ទរថា តើនៅស្រុកខ្មែរសព្វថ្ងៃ អនុវត្តសេដ្ឋកិច្ចជំនួញ ដែរឬទេ ?

ស្រុកខ្មែរសព្វថ្ងៃ ជា ប្រទេសតូចមួយ នៅក្នុងដំបន់ អាស៊ីផ្នែក អគ្នេយ៍ ហើយមានទម្ងន់សេដ្ឋកិច្ចតិចតួចបំផុតនៅក្នុងស៊ុម ពិភពលោកូបនីយកម្ម ជាពិសេសទៅទៀត ស្រុកខ្មែរកំពុងរស់ នៅក្នុងស្ថានភាព ជា រដ្ឋរស់ទីពឹងជំនួយ (Etat assisté) ក្នុងវិស័យ សេដ្ឋកិច្ច និងវិស័យដទៃច្រើនទៀត។ ចាប់ពី ទសវត្សរ៍៩០មក ស្រុកខ្មែរ ជ្រើសយក លទ្ធិប្រជាធិបតេយ្យសេរីជា របបដឹកនាំ ជាតិ និងសេដ្ឋកិច្ចជំនួញ ជា មធ្យោបាយ សំរាប់ធ្វើអភិវឌ្ឍន៍ ប្រទេស។ តើជម្រើសនេះ វា សមទៅតាម សេចក្តីត្រូវការរបស់ ស្រុកខ្មែរ ដែរឬទេ ? ស្រុកខ្មែរ ជា ប្រទេស មានចំណងប្រពៃណី មាំទាំ តែជា ប្រទេស រស់នៅក្នុង វាសនាវិនាសជ័យូរអង្វែង នាំ បំផ្លាញឲសាបសូន្យ នូវថាមពលជាតិដែលធ្វើឲប្រទេសមិនត្រឹម តែបាត់បង់ទឹកដី គឺថែមទាំងបាត់បង់បញ្ញារួមគ្នា ព្រោះ ខ្មែរ យើងខ្វះពេលវេលាគ្រប់គ្រាន់ សំរាប់ធ្វើបុនភាវកម្ម (régénérer) ការចេះដឹងត្រចេះត្រចង់ មាននៅក្នុងកំណប់ជាតិផង និង សិក្សាព្រមទាំងយល់ដឹង អំពីចំណេះថ្មី នៃមនុស្សជាតិផង។ ការ ពិការនេះហើយ ដែលនាំស្រុកខ្មែរឆាប់រងគ្រោះពី វិបត្តិផ្ទៃក្នុង និងកើតមកពីក្រៅ ហើយនៅពេលណាអ្នកដឹកនាំ គាត់ធ្វើ នយោបាយឆ្គោយអ្វីមួយ គឺច្បាស់ជា ពិបាកនឹងកែកំហុសនេះ ណាស់ ព្រោះប្រទេសតូច តែងតែខ្វះអត្ថមធ្យោបាយគ្រប់បែប

យ៉ាង ដើម្បីបន្ទុលស្ថានភាពខុសនេះ (redresser cette situation)។ នោះជាមាន អន្តរសង្គ្រោះ ក្នុងអំឡុងឆ្នាំ ១៩៩១-១៩៩៣ ដើម្បីបញ្ឈប់អត្តឃាត នៃជាតិខ្មែរ តាមមធ្យោបាយ ដាំ សន្តិភាពជាតិ និងប្រជាធិបតេយ្យនីយកម្ម នៃជីវិតភាពនយោបាយខ្មែរ យ៉ាងណាក៏ដោយ តែ វិរយះ (effort avec énergie) នេះ វាគ្មានមនុញ្ញផល (résultat satisfaisant) សំរាប់អនាគត ដែលអោយទុកចិត្តថា ប្រជាពលរដ្ឋខ្មែរ កំពុងដើរលើផ្លូវល្អ ឆ្ពោះទៅរកសេចក្តីសង្ឃឹមរបស់ខ្លួន ដូចយ៉ាង សន្តិភាពផ្គត់ផ្គង់ដោយច្បាប់សំរាប់ធានានូវសមធម៌ គឺ សិទ្ធិសេរីភាព ជា ប្រជាពលរដ្ឋធិបតេយ្យ និងយុត្តិធម៌ ដែលទាក់ទងនឹង ការរស់នៅរៀងរាល់ថ្ងៃ របស់ បណ្តាជនសាមញ្ញ។ តែថា សន្តិភាពនៅស្រុកខ្មែរសព្វថ្ងៃ ជា សន្តិភាពសំរាប់តែពួកអ្នកដឹកនាំ មិនអាចហូតងារបាន ឬបក្សកាន់អំណាច នៅក្នុងឳវាទយួន តែប៉ុណ្ណោះ។ មួយអន្លើងទៀតរបបដឹកនាំ នៅស្រុកខ្មែរសព្វថ្ងៃ វាគ្មានធាតុអ្វី ជា របបលទ្ធិប្រជាធិបតេយ្យបន្តិចបន្តួចសោះឡើយ តែវាយកឧបករណ៍ប្រជាធិបតីមកបំភាន់ប្រជាពលរដ្ឋ ដូចយ៉ាង ការបោះឆ្នោតបញ្ឆោត សំរាប់តែរក ភាពពេញច្បាប់ លើឆាកអន្តរជាតិតែប៉ុណ្ណោះ។ គម្លាតជាក់ស្តែង នៃសេចក្តីសង្ឃឹមរបស់ប្រជាពលរដ្ឋ នឹងការពិតនៅស្រុកខ្មែរសព្វថ្ងៃ វាជា ឧបសគ្គសំខាន់ដល់អភិវឌ្ឍន៍សំរាប់

ស្វែងរក ការរីកចំរើនដល់ប្រជាជាតិ និងសុខុមាលភាព នៃប្រជាពលរដ្ឋ។ ជាឧទាហរណ៍ អំពីសន្តិភាព គឺមិនមែនឋិតនៅលើរូបភាព របស់លោក ហ៊ុន សែន អង្គុយហូបគុយទាវ នៅក្នុងហាងបាយយួន មាន អង្គរក្សឈរព័ទ្ធជុំវិញ សំរាប់ការពារសុវត្ថិភាពរបស់គាត់ នៅចំពោះបណ្តាជន ឈរមើលគាត់ ដូចឈរមើល របា (ទស្សនីយភាព) ចិនប៉ាហ៊ី នៅផ្សារត្រីនោះឡើយ។ សន្តិភាពពិត គឺ នៅក្នុងគុក គ្មានអ្នកទោសមនសិការ និងក្នុងនគរ គ្មានឃាតកម្ម លើអ្នកស្នេហាជាតិ មានវិស័យមតិការពារជាតិ។ រីឯ ឧទាហរណ៍ អំពីលទ្ធិប្រជាធិបតេយ្យ វិញគឺមិនមែនឋិតនៅលើ អត្ថភាព នៃស្ថាប័នរៀបរាប់ឈ្មោះ នៅក្នុងរដ្ឋធម្មនុញ្ញ តែប៉ុណ្ណោះទេ។ ប្រជាធិបតីជាយថាភូត គឺ អនុវត្ត និងគោរពច្បាប់ជាតិ និងអន្តរជាតិ ក្នុងនាមប្រជាពលរដ្ឋ អោយបានពិតប្រាកដ។ លើសពីនេះទៅទៀត ត្រូវយកលទ្ធិប្រជាធិបតេយ្យនយោបាយ ជា មូលដ្ឋានសំរាប់បង្កើត លទ្ធិប្រជាធិបតេយ្យសេដ្ឋកិច្ច និងសង្គម ក្នុងគោលដៅ សំរាប់បណ្តេញ កំចាត់ឈ្មួញទុច្ចរិត និងអ្នកដឹកនាំពុករលួយ ដើម្បី ប្រយោជន៍ទូទៅ និងប្រយោជន៍ជាតិ។ មួយវិញទៀត ប្រជាធិបតី ជាយថាភូត ត្រូវមាននីតិរដ្ឋ មានអង្គការសារពត៌មានឯករាជ្យ នៅចំពោះមុខអាជ្ញាធរ, អំណាចឧកញ៉ា និងមិននៅក្រោម ឥទ្ធិពលបរទេ

ស។ សេចក្តីខ្វះ នៃមូលដ្ឋាន ជាសារវន្តទាំងនេះឯង ដែលនាំអោយសេដ្ឋកិច្ចជំនួញនៅស្រុកខ្មែរ លុះភាព ជា សេដ្ឋកិច្ចរបស់ពួកនាយទន់បរទេស និងឧកញ្ញា គិតតែបោយយកចំណេញ លើសេចក្តីវិនាសរបស់ កម្មករទាស (ouvriers d'esclaves) កសិករក្ររហាម អ្នករាជការ ដែលនៅក្រោមបង្គាប់ ពួកឯកឧត្តមពុករលួយ។ សេដ្ឋកិច្ចជំនួញបែបនេះ គ្មានចក្ខុវិស័យសំរាប់អនាគតជាតិនោះឡើយ ព្រោះពួកអ្នកវិនិយោគ គេគិតតែនាំគ្នាឆ្លៀត ទាញយកផលប្រយោជន៏ពី ធនធានធម្មជាតិ ដែលមានកំណត់ និងហត្ថពលមាន តម្លៃថោក។ នៅទីបញ្ចប់ វានាំបំផ្លាញ ដល់ធនធានធម្មជាតិ មានជាអាច ព្រៃឈើ រ៉ែ ជលសា ម្រឹទិនី (ដីមានជីជាតិល្អ) ដែលសុទ្ធជាសាធារណូបករណ៏របស់ប្រជាពលរដ្ឋខ្មែរ។ ម៉្យាងមួយទៀត លក្ខណៈនៃការប្រព្រឹត្តិការងារ បីដូច អ្នកជាប់ទោសឧក្រិដ្ឋ ដែលត្រូវបង្ខំឲធ្វើការធ្ងន់វាធ្វើអោយសោះពល់និងប្រជ្ញាកម្មករ រស់នៅគ្មានទស្សនវិស័យ ដល់អនាគត សំរាប់ជីវិត នៅពេលក្រោយ មានអាយុចាប់ពី៣០ឆ្នាំឡើងទៅ ព្រោះសព៌ាង្គកាយ ទៅជា មនុស្សចាស់មុនអាយុ និងប្រាជ្ញា ចុះទន់ខ្សោយ ដែលនាំឲក្លាយ ជា ចំណីរបស់ជម្ងឺគ្រប់បែបយ៉ាង។ យើងអាចទុកសេដ្ឋកិច្ចជំនួញនៅស្រុកខ្មែរ ជា ថ្នាំពលមានខ្ចាតតូច

តែគ្រប់គ្រាន់ សំរាប់សម្លាប់បណ្តើរៗ ប្រជាជាតិខ្មែរ នៅក្នុងអនាគតដ៏ខ្លីមួយ។

## កត្តាដែលនាំបង្កើតស្ថានការណ៍

អ្វីដែលពិបាកនឹងជឿបាន គឺ សព្វថ្ងៃនេះ ខ្មែរយើងហាក់បីដូចជាទុកជីវិតឥតន័យរបស់ខ្លួនជាកម្មផល នាំគ្នាលះបង់សិទ្ធិខ្លួនឲអ្នកដឹកនាំជាតិ និងអ្នកនយោបាយ ជា អ្នកសម្រេច លើជោគវាសនារបស់ខ្លួន ហើយនាំគ្នាយក លាភសន្តោស (សេចក្តីត្រេងអរចំពោះតែត្រឹមលាភរបស់ខ្លួន) ជា ផ្លូវជីវិត គឺថា រស់មិនគិតដល់ថ្ងៃស្អែក (រស់មួយគែ) អត់ធ្មត់ទ្រាំទ្រ ចំពោះទុក្ខប្រចាំជីវិត និងអយុត្តិធម៌សង្គមគ្រប់បែបយ៉ាង។ ជីវិតរស់នៅ នៃប្រជាពលរដ្ឋខ្មែរសព្វថ្ងៃ បីដូច ជាជីវិតរស់នៅក្នុង រត្តភាគ (ពេលតែមួយរាត្រី) សំរាប់តែយល់សប្តិ ឃើញ ផាសុវិហារ (ការនៅជាសុខសម្បាយ) តែប៉ុណ្ណោះ។ អ្វីដែលខ្មែរយើងចង់បាន វាមាននៅតែក្នុងសុបិន ផ្ទុយទៅវិញអ្វីដែលខ្មែរយើងមិនចង់ជួបប្រទះនៅក្នុងជីវិត វាជាការពិតសំរាប់ការរស់នៅរៀងរាល់ថ្ងៃរបស់ខ្លួន។ ទុក្ខ និងការលំបាកគ្រប់បែបយ៉ាង វាជា ជីវិតរស់នៅធម្មតារបស់ខ្មែរយើងនោះឯង។ នៅក្នុង ប្រាង្គណ៏ (ទិវាលជាធ្លា, espace) នៃការសង្ឃឹមរបស់ខ្មែរយើងសព្វថ្ងៃ គឺនៅត្រឹមតែធ្វើយ៉ាងណា អោយបានហូប បានឆ្អែត

មួយពេល ដោយមិនគិតដល់រស់ជាតិឆ្ងាញ់ពិសា នៃម្ហូបចំណី ដែលខ្លួនបរិភោគនោះឡើយ។ រូបភាព នៃភិយ្យោភាព នៃចំណី ចំណុកលើភាជន៍ គឺវាមានពិត តែសំរាប់ វណ្ណៈអ្នកដឹកនាំ និង ឧកញ្ញាមួយក្តាប់ នៅក្នុងសង្គមមានសុទ្ធតែអ្នកខ្សត់ពេញមួយ នគរ។ ស្ថានភាពនេះ គឺកើតមកពី ការចែកចំណែកផល នៃ អភិវឌ្ឍន៏ មិនប្រកបដោយសមធម៌ ដែលនាំអោយអ្នកក្រគ្មាន លទ្ធភាពដើរចេញរួចពីភពនៃទលិទ្ទភាព (ភាពក្រ) ដែលជាភព ប ញ្ចេញឥទ្ធិពលកំណាច ដល់ជីវិតរស់នៅ។ ការណ៏នេះ វាគ្រាន់តែ ជាចំណែកមួយតែប៉ុណ្ណោះ ព្រោះវានឹងមាន កត្តាជាច្រើនទៀត ដូចយ៉ាង៖

## អប្បបញ្ញាធិបតី[4] នៃអ្នកដឹកនាំ និងបុគ្គលិកនយោបាយ

នៅស្រុកខ្មែរ ការកាន់ដំណែង មិនអាចហួតងារបាន នៃពួក អ្នកដឹកនាំសព្វថ្ងៃ នាំអោយ ក្រិនប្រាជ្ញា។ ស្តិរភាពនយោបាយ មានពិត តែដូចជាទឹកស្អុយនៅក្នុងអាងទឹក គ្មានប្រយោជន៍ សំរាប់ពិសា មិនតែប៉ុណ្ណោះ វាថែមទាំង ជះក្លិនស្អុយ ធ្វើឲពុល ខ្យល់អាកាស បណ្តាលអោយមានជម្ងឺគ្រប់បែបយ៉ាង។ ស្តិរភាព

[4] អប្បបញ្ញាធិបតី, médiocratie, ភាពអន់ជាធិបតី។

បែបនេះធ្វើឲអោក់ខាន នូវការផុសឡើង នៃបញ្ញាជាតិថ្មី ដែលជាចលករ នៃអភិវឌ្ឍន៏។ អំណាចណាមួយ ដែលគ្មានកំរិតពេលវេលា ជា អំណាចផ្តាច់ការ ហើយអូសប្រទាញ ទៅរក សេដ្ឋកិច្ចអតិថិជននិយម (économie clientéliste) បង្កើតអោយមាន ក្រុមម៉ាហ្វា ក្នុងមាត្រដ្ឋាននៃរដ្ឋ ដែលដឹកនាំដោយ ញាតិមិត្ត ឬ កូនចៅរបស់ពួកអ្នកដឹកនាំ ប្រើអំពើពុករលួយ ជា ច្បាប់ នៃសេដ្ឋកិច្ច ប្រើអាវុធ ជា តុលាការ ដើម្បី វិបុលភាព នៃគ្រួសារខ្លួន តែវាជា សេចក្តីវិនាសដល់សេដ្ឋកិច្ចជាតិ។

រីឯ បុគ្គលិក អ្នកនយោបាយ (personnel politique) វិញ ជាពិសេសនៅក្នុងជួរ គណបក្សប្រឆាំង មាននិន្នាការនយោបាយ យ៉ាងណាក្តី គឺពួកគាត់គ្មាន រូបសញ្ញា (marqueur) អ្វី ដែលបញ្ជាក់អោយឃើញច្បាស់លាស់ នូវបដិយោគនឹង ពួកអ្នកដឹកនាំផ្តាច់ការ ព្រោះនាំគ្នាសម្ងំរស់នៅក្នុងបរិស្ថាន ដែលពួកនោះ គេបង្កើតឡើង ដូចយ៉ាង ការប្រើពាក្យសំដី, ពាក់ងារកិត្តិយស ជា ឯកឧត្តម ជំទាវ, ឆ្លៀតទទួលយក អត្ថប្រយោជន៍ គ្រប់បែបយ៉ាងពី របបហុតឈាមរាស្ត្រ និងប្រើឧបាយបញ្ឆោតប្រជាពលរដ្ឋជារូបភាពក្តី ជាសំដីក្តី ដើម្បីការពារតែបុព្វសិទ្ធិខ្លួនប៉ុណ្ណោះ។ ពួកគាត់ ភាគច្រើន ជា អ្នកសីហនុនិយម ហើយ នៅតែមាន ជំនឿផ្កាប់មុខ

លើគំរូ នៃទ្រឹស្តីនយោបាយ របស់សពសម្តេចសីហនុ ថាជាដំណោះស្រាយថ្ជូនល្មមនឹង បញ្ហាមាននៅស្រុកខ្មែរ តែមិនដែលបង្ហាញអោយឃើញច្បាស់ នូវលទ្ធផលជាក់ស្តែង ដូចយ៉ាង សន្តិភាព,ការផ្សះផ្សាជាតិ, ឯករាជ្យជាតិ, ការរក្សាបូរណភាពដែនដីជាតិ, ប្រយោជន៍ជាតិ និងរាជានិយម ប្រកបដោយសេចក្តីថ្លៃថ្នូរ និងមានប្រយោជន៍ដល់សង្គមខ្មែរ។ នៅក្នុងជួរ គណបក្សប្រឆាំង គ្មានការពិភាក្សាសាផ្ទុយមតិគ្នា (débat contradictoire) គ្មានការពិភាក្សានៃបញ្ញា (débat intellectuel) ព្រោះ ជា គណបក្សមាន នរបតី (maître) ជាអ្នករ៉ាប់រងដាច់ថ្លៃ គឺថា ទុកអ្នកស្ម័គ្រចិត្ត ចូលជាសាមាជិក ត្រឹមតែ ជាអ្នកចុះចូលខ្លួន ឬ ជាអ្នកគុណូបការជាហិរញ្ញវត្ថុ (soutien financier) តែប៉ុណ្ណោះ។ អ្នកដឹកនាំគណបក្សប្រឆាំង ក៏ជា អ្នកកាន់ដំណែង មិនអាចហូតងារបាននោះដែរ ដែលនាំអោយពួកគាត់ បន្តប្រព្រឹត្តិកំហុសគាត់មិនឈប់ឈរ បើកលទ្ធភាព អោយគណបក្ស កាន់អំណាចផ្តាច់ការពង្រឹងអំណាច របស់គេកាន់តែមាំមួនឡើងៗ ដែលជា កម្លាំងមួយសំរាប់ រំលស់ប្រាង្គណ៏ នៃគំនិតផ្តើមនយោបាយ (réduire l’espace d’initiative politique) របស់ខ្លួន របាយស្ទើរតែទាំងអស់ នៅសល់តែសេចក្តីសង្ឃឹម លើការបោះឆ្នោតនៅក្នុងរបបផ្តាច់ការ និងរង់ចាំ ឧបាស្រ័យអនុគ្រោះ (recours en grâce) ពីព្រះមហាក្សត្រ និង

លោក ហ៊ុន សែន  ដល់មគ្គុទេសទាំងពីរ  ដែលជាអ្នកជាប់ចោទ អយុត្ត នៃអនីត្យានុកូលបទ (délit civil) តែប៉ុណ្ណោះ។ ចំនួនតំណាងរាស្ត្រ៥៥  ដែលអាចជា  ទន្ទ្បះកម្លាំងនយោបាយ  សំរាប់ការពារប្រយោជន៏ជាតិ បែរជាប្រែក្លាយ ជា បេសកកម្ម នៃការចរចា សំរាប់ស្វែងរក សេចក្តីសុខអាត្មា ដែលវាផ្ទុយពីសេចក្តីប្រាថ្នា របស់ប្រជាពលរដ្ឋ។  មកដល់សព្វថ្ងៃ តួនាទីចម្បង  ជា  អ្នកសង្គ្រោះជាតិ  ជាប្រមុខ  បែរទៅជា  អ្នកសម្ងំបួន  រង់ចាំអោយ  ប្រជាករសង្គ្រោះខ្លួនទៅវិញ។  អាកុលកម្ម  (méfaits) ដែលបានប្រព្រឹត្តិ  ជាច្រើនមកដល់សព្វថ្ងៃនេះ  វាមិនជានានូវសេចក្តីសង្រ្គឹម  សំរាប់អនាគតកាលជាតិនោះឡើយបើពួកអ្នកដឹកនាំចលនាប្រឆាំងគ្រប់គោលគំនិតនយោបាយ គាត់នៅតែធ្វើ ចរាចរ  (ដើរទៅវិញទៅមក, aller et venir) នៅក្នុងយុទ្ធសាស្ត្រយួន រហូតមកដល់សព្វថ្ងៃនេះ។ អ្វីដែលយើងសរសេរខាងលើនេះ  មិនមែនជាការវិនិច្ឆ័យទុកជាមុននោះឡើយ  ព្រោះ  វាជា  ឧយ្យោគ  ឬ  ដេញតាម  (poursuite)  រកប្រយោជន៏ផ្ទាល់ខ្លួន ជាទម្លាប់ របស់អ្នកនយោបាយភាគច្រើននៅស្រុកខ្មែរសព្វថ្ងៃ។  សួរថា តើ  ពួកឯកឧត្តម/ជំទាវ  នៃគណបក្សប្រឆាំង  តើគាត់អាច  ជា  ការវៀរបង់  (exception)  ដែរឬទេ ? បើអ្នកដឹកនាំជាតិ និងអ្នកប្រឆាំង  ជាមនុស្សស្វែងតែរកលុយគឺច្បាស់ជា លុយក្រខ្វក់ វាហូរចេញពី ប្រភពឈ្លួញទុច្ចរិត មករក

អ្នកលោក ចង់បានច្រើនជានិច្ចជាពុំខាន ព្រោះរបបដឹកនាំសព្វថ្ងៃ មានធាតុ ជា របបអាសុចភាព[5] ដែលអនុគ្រោះ អោយមានចរាចរណ៍ នៃទ្រព្យក្រខ្វក់បែបនេះ នៅក្នុងសង្គមខ្មែរ។

## សេចក្តីបញ្ចប់

នៅក្នុង ការសាកល្បងពិនិត្យរបស់យើងនេះ យើងមិនឲយោបល់ ជា សេចក្តីសន្និដ្ឋាននោះទេ ព្រោះបញ្ហា ដែលបានរៀបរាប់ខាងលើនេះ ជាកិច្ចការ របស់ប្រជាពលរដ្ឋខ្មែរ ដូច្នេះខ្មែរម្នាក់ៗ ធ្វើសេចក្តីសន្និដ្ឋានទៅតាម វេទយិតភាព (sensibilité) របស់ខ្លួនរៀងៗខ្លួន នៅក្នុងគោលគំនិត ទុកប្រយោជន៍ជាតិជាធំ។ តាមគោលការណ៍ ជនខ្មែរម្នាក់ តែងតែស្រឡាញ់ប្រទេសខ្លួន សាសន៍ជាតិខ្លួន ពិតប្រាកដ ដូច្នេះ ការទុក ប្រយោជន៍ជាតិជាធំ វាជា ប្រត្យក្សភាព (évidence) សំរាប់ប្រជាជាតិខ្មែរ។ ចុះហេតុអ្វី បានជានៅមានជានិច្ច របបផ្តាច់ការនៅស្រុកខ្មែរ ហើយជា ប្រទេស រស់នៅក្រោមអាណាគមយួន ? សំនួរទាំងពីរនេះ តើវាជា រូបភាពពិត នៃអភិវឌ្ឍន៍នៅស្រុកខ្មែរ ?

---

5 អាសុចភាព: ភាពទុច្ចរិត, ភាពកខ្វក់, សេចក្តីស្មោកគ្រោក។